វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- ការប្រើប្រាស់កាតឥណទានUnionPayដែលមានមូលដ្ឋាននៅប្រទេសចិន មានការកើនឡើងឆាប់រហ័សនៅកម្ពុជា
- ប្រទេសវៀតណាម និងឥណ្ឌា កំណត់ទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឥណ្ឌា-អាស៊ាន
- ធនាគារសហព័ន្ធបានចេញសារព្រមានលើស្ថេរភាពនៃហិរញ្ញវត្ថុ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការប្រើប្រាស់កាតឥណទានUnionPayដែលមានមូលដ្ឋាននៅប្រទេសចិន មានការកើនឡើងឆាប់រហ័សបំផុតនៅប្រទេសកម្ពុជា

បណ្តាញទូទាត់តាមកាតឥណទាន(UnionPay) ដែលមានមូលដ្ឋាននៅប្រទេសចិនបានបង្ហាញថា កម្ពុជាគឺជាទីផ្សាររបស់ខ្លួនដែលរីកលូតលាស់លឿនបំផុតនៅក្នុងអាស៊ីអាគ្នេយ៍។ ចំនួននៃការធ្វើប្រតិបត្តិការកាតឥណទានUnionPay បានកើនឡើងជិតពីរដងក្នុងចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨។ កំណើននេះភាគច្រើនបណ្តាលមកពីការកើនឡើងនៃចំនួនប្រជាជនកម្ពុជាដែលធ្វើដំណើរទៅក្រៅប្រទេសក្នុងកំឡុងពេលវិស្សមកាល។

ប្រជាជនកម្ពុជាដែលប្រើប្រាស់កាតឥណទានUnionPay ភាគច្រើនបានប្រើប្រាស់កាតនេះនៅប្រទេសចិន ថៃ និងប្រទេសសឹង្ហបុរី។ ប្រតិបត្តិការដែលបានប្រើប្រាស់ទាំងក្នុងប្រទេស និងក្រៅប្រទេសសម្រាប់កម្ពុជាបានកើនឡើងប្រមាណ៤៩%ក្នុងរយៈពេល១០ខែដំបូងក្នុងឆ្នាំ២០១៨នេះ។ រីឯប្រតិបត្តិការរបស់អ្នកប្រើប្រាស់កាតឥណទានUnionPay ដោយជនជាតិបរទេសនៅក្នុងប្រទេសកម្ពុជាបានកើនឡើងជាង ៥៤%ក្នុងរយៈពេលដូចគ្នា។

បច្ចុប្បន្ននេះ កាតឥណទានUnionPay ត្រូវបានទទួលស្គាល់ក្នុងការប្រើប្រាស់ប្រមាណ៩០%ក្នុងប្រព័ន្ធលក់រាយ និង៨០%តាមម៉ាស៊ីនស្វ័យប្រវត្តិ(អេធីអឹម) បើគិតចាប់តាំងពីបានចូលក្នុងទីផ្សារកម្ពុជាកាលពីមួយទស្សវត្សរ៍មុន។

### **តារាងប្រចាំសប្តាហ៍៖** ការនាំចេញរបស់ប្រទេសជាសមាជិកអាស៊ាន ទៅក្នុងតំបន់ និងទៅបរទេស

តារាងក្នុងសប្តាហ៍នេះ បង្ហាញពីការនាំចេញរបស់ប្រទេសដែលជាសមាជិកអាស៊ានទៅប្រទេសក្នុងតំបន់ និងប្រទេសក្រៅតំបន់អាស៊ាន នៅក្នុងឆ្នាំ២០១៧ គិតជាភាគរយនៃការនាំចេញសរុប។

## ការនាំចេញទំនិញទៅតាមគោលដៅ ឆ្នាំ២០១៧ (គិតជា%)




ប្រភព៖ ផ្នែកស្ថិតិ អាស៊ាន (ASEANstats)

ភាគច្រើននៃការនាំចេញរបស់ប្រទេសតំបន់អាស៊ាន មានគោលដៅទៅក្រៅតំបន់ លើកលែងតែប្រទេសឡាវ ដែលការនាំចេញទៅក្នុងតំបន់អាស៊ានមានចំនួន ៥០,៨%នៃការនាំចេញសរុប។

សម្រាប់កម្ពុជា ការនាំចេញទៅកាន់ប្រទេសដែលនៅក្នុងតំបន់អាស៊ានដូចគ្នាមានត្រឹមតែ១០%ប៉ុណ្ណោះ ដែលនេះអាចបង្ហាញពីឱកាសដែលគួរបង្កើនកិច្ចការពាណិជ្ជកម្មក្នុងតំបន់។ ជាមធ្យម ការនាំចេញរបស់ប្រទេសក្នុងអាស៊ានទៅក្រៅតំបន់មានប្រហែលជា ៧៧% នៃការនាំចេញសរុប។

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ប្រទេសវៀតណាម និងឥណ្ឌា កំណត់ទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឥណ្ឌា-អាស៊ាន

យោងតាមអ្នកជំនាញឧស្សាហកម្មដែលបានថ្លែងនៅក្នុងព្រឹត្តិការណ៍មួយកាលពីសប្តាហ៍មុនបានឱ្យដឹងថា ប្រទេសវៀតណាម និងឥណ្ឌាកំពុងសម្លឹងមើលការរីកចម្រើនផ្នែកពាណិជ្ជកម្មវាយនភ័ណ្ឌទ្វេភាគីរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ឥណ្ឌា-អាស៊ាន ដែលអនុញ្ញាតឱ្យមានការនាំចូលនូវផលិតផលវាយនភ័ណ្ឌដោយមិនយកពន្ធ ដែលនឹងចាប់ផ្តើមនៅឆ្នាំ២០១៩។
ប្រទេសវៀតណាមស្ថិតក្នុងចំណោមប្រទេសឈានមុខគេទាំង៥ ដែលនាំចេញសំលៀកបំពាក់ និងវាយនភ័ណ្ឌ និងមានតម្រូវការវត្ថុធាតុដើមច្រើន ហើយប្រទេសនេះកំពុងស្វែងរកការធ្វើពិពិធកម្មអ្នកផ្គត់ផ្គង់របស់ខ្លួន។
ការនាំចេញរបស់ប្រទេសឥណ្ឌាទៅកាន់ប្រទេសវៀតណាម បានកើនឡើងជិត៥០%នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយនេះ ដែលមានទឹកប្រាក់ដល់ទៅ ៥៥៥ លានដុល្លារ។ ការនាំចេញសរុបរបស់វៀតណាម បានកើនឡើងដល់ ៣១ ប៊ីលានដុល្លារក្នុងរយៈពេលដូចគ្នា ពោលគឺកើនឡើង១០% ធៀបនឹងឆ្នាំមុន។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## ធនាគារសហព័ន្ធបានចេញសារព្រមានអំពីស្ថេរភាពនៃហិរញ្ញវត្ថុ

កាលពីថ្ងៃពុធកន្លងទៅនេះ ធនាគារសហព័ន្ធបានចេញផ្សាយនូវរបាយការណ៍ដាស់តឿនអំពីហានិភ័យរបស់ប្រព័ន្ធហិរញ្ញវត្ថុ។ របាយការណ៍នេះបានថ្លែងពីភាពមិនប្រាកដប្រជាមួយចំនួន ដូចជា ភាពតានតឹងពាណិជ្ជកម្មដែលកំពុងបន្តរវាងអាមេរិក និងចិន ភាពមិនច្បាស់លាស់នៃបរិស្ថានភូមិសាស្រ្តនយោបាយ និងការកើនឡើងនៃបំណុលសាជីវកម្មរបស់ក្រុមហ៊ុនដែលមានតារាងតុល្យការទន់ខ្សោយ ដែលទាំងនេះជាការគំរាមកំហែងទៅលើស្ថេរភាពនៃហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។

របាយការណ៍នេះ បានបង្ហាញពីឥទ្ធិពលនៃហានិភ័យដែលអាចនាំឲ្យមានការធ្លាក់ចុះយ៉ាងខ្លាំងនូវតម្លៃនៃទ្រព្យសកម្មនានា។ ធនាគារសហព័ន្ធក៏បានកត់សម្គាល់បន្ថែមថា ការកើនឡើងយ៉ាងខ្លាំងនៃអត្រាការប្រាក់របស់ខ្លួន ក៏នឹងអាចប៉ះពាល់ទៅលើទីផ្សារដែលធ្លាប់តែមានអត្រាការប្រាក់ទាប។

ទោះជាបែបនេះក្តី របាយការណ៍បានសន្និដ្ឋានថា វិស័យហិរញ្ញវត្ថុស្ថិតនៅក្នុងភាពរឹងមាំជាងបើប្រៀបធៀបទៅនឹងកំឡុងពេលមុនមានវិបត្តិហិរញ្ញវត្ថុសកលលោក។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សប្តាហ៍ក្រោយនឹងបង្ហាញពីអត្រាអតិផរណានៅក្នុងអាស៊ី ដែលមានដូចជា៖ ប្រទេសឥណ្ឌូនេស៊ី ប្រទេសកូរ៉េខាងត្បូង ប្រទេសហ្វីលីពីន និងប្រទេសតៃវ៉ាន់។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុមFACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី០៣ ខែធ្នូ ឆ្នាំ២០១៨

- ការចំណាយផ្នែកមូលធន របស់ជប៉ុន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- សន្ទស្សន៍ការគ្រប់គ្រងការបញ្ជាទិញ(PMI) របស់ឥណ្ឌូនេស៊ី សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍ភាពជឿជាក់ទៅលើពាណិជ្ជកម្មរបស់ថៃ សម្រាប់ខែវិច្ឆិកា
- អត្រាអតិផរណារបស់ឥណ្ឌូនេស៊ី សម្រាប់ខែវិច្ឆិកា

ថ្ងៃអង្គារ ទី០៤ ខែធ្នូ ឆ្នាំ២០១៨

- ទិន្នន័យចំនួនលក់រថយន្តសរុបរបស់អាមេរិក សម្រាប់ខែវិច្ឆិកា
- កំណើនផ.ស.ស. របស់កូរ៉េខាងត្បូង សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- អត្រាអតិផរណារបស់កូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍តម្លៃលក់រាយរបស់ហ្វីលីពីន សម្រាប់ខែតុលា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រ៊ុយណេ សម្រាប់ខែកញ្ញា

ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០១៨

- ទិន្នន័យទុនបំរុងបរទេសរបស់កូរ៉េខាងត្បូង សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍ការគ្រប់គ្រងការបញ្ជាទិញ(PMI) Nikkei របស់ហុងកុង សម្រាប់ខែវិច្ឆិកា
- អត្រាអតិផរណារបស់ហ្វីលីពីន សម្រាប់ខែវិច្ឆិកា
- អត្រានិកម្មភាពរបស់ហ្វីលីពីន សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- អត្រាអតិផរណា របស់តៃវ៉ាន់ សម្រាប់ខែវិច្ឆិកា
- តុល្យភាពពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែតុលា

ថ្ងៃព្រហស្បតិ៍ ទី០៦ ខែធ្នូ ឆ្នាំ២០១៨

- របាយការណ៍សង្ខេបសេដ្ឋកិច្ចបច្ចុប្បន្នតាមតំបន់(ស្រុក/ខណ្ឌ) (beige book) ដែលចេញផ្សាយដោយធនាគារសហព័ន្ធអាមេរិក
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់ របស់ថៃ សម្រាប់ខែវិច្ឆិកា
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់ របស់ហ្វីលីពីន សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- សន្ទស្សន៍ភាពជឿជាក់របស់អ្នកប្រើប្រាស់ របស់ឥណ្ឌូនេស៊ី សម្រាប់ខែវិច្ឆិកា

ថ្ងៃសុក្រ ទី០៧ ខែធ្នូ ឆ្នាំ២០១៨

- ទិន្នន័យការចំណាយតាមគ្រួសាររបស់ជប៉ុន សម្រាប់ខែតុលា
- សន្ទស្សន៍សូចនាករសេដ្ឋកិច្ចឈានមុខរបស់ជប៉ុន សម្រាប់ខែតុលា
- ទិន្នន័យទុនបំរុងបរទេសរបស់ហ្វីលីពីន សម្រាប់ខែវិច្ឆិកា
- ទិន្នន័យទុនបំរុងបរទេសរបស់ថៃ សម្រាប់ខែវិច្ឆិកា
- តុល្យភាពពាណិជ្ជកម្មតៃវ៉ាន់ សម្រាប់ខែវិច្ឆិកា
- ទិន្នន័យទុនបំរុងបរទេសរបស់សិង្ហបុរី សម្រាប់ខែវិច្ឆិកា
- ការចំណាយរបស់រដ្ឋាភិបាលអាមេរិកទៅលើប្រាក់ខែ សម្រាប់ខែវិច្ឆិកា ៕